## ៦-ការផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ

☞ ដើម្បីស្នើសុំប្រើប្រាស់ **ការផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ** លោកអ្នកត្រូវចូលទៅកាន់គេហទំព័រ https://lacms.mlvt.gov.kh រួចចុចលើសេវាលេខរៀងទី៦ ដូចខាងក្រោម៖




☞ បន្ទាប់ពីចុចលើសេវាលេខរៀងទី៦រួចមក នោះប្រព័ន្ធនឹងបង្ហាញការស្នើសុំប្រើប្រាស់ **ការផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ** ជា ២ជម្រើសដូចខាងក្រោម៖



# ៦.១-ការស្នើសុំក្នុងនាមជារោងចក្រ សហគ្រាស

## ៦.១ ការផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ (ក្នុងនាមជារោងចក្រ សហគ្រាស)

១ ចូលទៅកាន់គេហទំព័រ https://lacms.mlvt.gov.kh

២ សូមជ្រើសរើសយក ការផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ

៣ បំពេញអ៊ីមែល និងលេខសម្ងាត់

៤ បំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវ

- ឯកសារតម្រូវ៖
  - ១. វិញ្ញាបនបត្រពិនិត្យកាយសម្បទា ចំនួន ១ច្បាប់
  - ២. វិញ្ញាបនបត្រមុខរបរកម្មករនិយោជិតខ្មែរដែលចេញដោយនិយោជក ចំនួន ១ច្បាប់
  - ៣. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លង) ចំនួន ១ច្បាប់
    ឬសៀវភៅគ្រួសារ ឬសេចក្តីចម្លងសំបុត្រកំណើត (ច្បាប់ថតចម្លង) ចំនួន ១ច្បាប់
  - ៤. រូបថតចំពីមុខ (៤x៦) ចំនួន ១សន្លឹក
- សូមបំពេញលេខវិញ្ញាបនបត្រពិនិត្យកាយសម្បទា ពេលនោះប្រព័ន្ធនឹងទាញទិន្នន័យមួយចំនួនរបស់កម្មករនិយោជិតដោយស្វ័យប្រវត្តិ
- ចំពោះទិន្នន័យដែលនៅសល់ សូមបំពេញបន្ថែមដូចខាងក្រោម៖
  - ✓ កម្រិតវប្បធម៌
  - ✓ ព័ត៌មានការងារ
  - ✓ ស្កេនឯកសារវិញ្ញាបនបត្រមុខរបរកម្មករនិយោជិតខ្មែរ និងភ្ជាប់ទៅក្នុងប្រព័ន្ធ

៥ បង់ប្រាក់ថ្លៃសេវាតាមរយៈអនឡាញជាមួយធនាគារដែលជាដៃគូសហការរបស់ក្រសួង

៦ រង់ចាំការឆ្លើយតបក្នុងរយៈពេល១០ថ្ងៃ នៃថ្ងៃធ្វើការ

៧ ទទួលបានសៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ



ជោគជ័យ




1. បញ្ចូលអ៊ីមែល និងលេខសម្ងាត់ដែលលោកអ្នកបានបង្កើត នៅពេលចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ
2. ចុចលើពាក្យថា "**ចូល**" ដើម្បីចូលស្នើសុំប្រើប្រាស់សេវា

☞ បន្ទាប់ពីចុចលើពាក្យថា "**ចូល**" រួចមក នោះប្រព័ន្ធនឹងបង្ហាញដូចខាងក្រោម៖



① **ព័ត៌មាននៅក្នុងប្រអប់ពណ៌ក្រហម៖** ជាទិន្នន័យដែលទាញយកមកដោយស្វ័យប្រវត្តិ បន្ទាប់ពីបញ្ចូលលេខឯកសារវិញ្ញាបនបត្រពិនិត្យកាយសម្បទា

② **ព័ត៌មាននៅក្នុងប្រអប់ពណ៌ខៀវ៖** ជាទិន្នន័យដែលត្រូវបំពេញបន្ថែម ដូចជាកម្រិតវប្បធម៌ និងព័ត៌មានការងារ និងត្រូវទាញយកគំរូវិញ្ញាបនបត្រមុខរបរ ដើម្បីឱ្យរោងចក្រ សហគ្រាសបញ្ជាក់ រួចស្កេនភ្ជាប់មកប្រព័ន្ធវិញ ក្នុងទម្រង់ជា JPG, JPEG, PDF ដែលមានទំហំក្រោម 5MB

③ ចុចលើពាក្យថា "**រក្សាទុក និងបញ្ចូលបន្ថែមបុគ្គលិកថ្មី**" ដើម្បីរក្សាទុកព័ត៌មានដែលបានបំពេញ និងបញ្ចូលព័ត៌មានកម្មករនិយោជិតបន្ថែមទៀត ប្រសិនជាមានការស្នើសុំប្រើប្រាស់សេវាលើសពី ១នាក់

④ ចុចលើពាក្យថា "**រក្សាទុក និងចាកចេញ**" ដើម្បីរក្សាទុកព័ត៌មានដែលបានបំពេញទៅក្នុងបញ្ជីកំពុងរៀបចំស្នើសុំ

⑤ ចុចលើពាក្យថា "**ចាកចេញ**" ដើម្បីបោះបង់ការស្នើសុំប្រើប្រាស់សេវា

☞ បន្ទាប់ពីចុចលើពាក្យថា “**រក្សាទុក និងចាកចេញ**” រួចមក នោះប្រព័ន្ធនឹងបង្ហាញដូចខាងក្រោម៖




① ចុចសញ្ញា ☑ នៅខាងមុខឈ្មោះកម្មករនិយោជិត *(ជ្រើសរើសច្រើនបំផុតត្រឹម ៣០នាក់ក្នុង ១សំណើ)* ដើម្បីស្នើសុំប្រើប្រាស់សេវា សម្រាប់កម្មករនិយោជិតទាំងអស់នោះ

② ចុចលើពាក្យថា “**បញ្ជូនពាក្យស្នើសុំ**” ដើម្បីបញ្ជូនពាក្យស្នើសុំទៅក្នុងប្រព័ន្ធ

③ ចុចលើពាក្យថា “**លុបពាក្យស្នើសុំ**” ដើម្បីលុបពាក្យស្នើសុំចេញពីប្រព័ន្ធ

☞ បន្ទាប់ពីចុចលើពាក្យថា “**បញ្ជូនពាក្យស្នើសុំ**” រួចមក នោះប្រព័ន្ធនឹងបង្ហាញដូចខាងក្រោម៖




- លោកអ្នកនឹងទទួលបានសារបញ្ជាក់ថាសំណើរបស់អ្នកត្រូវបានបញ្ជូនដោយជោគជ័យទាំងនៅក្នុងប្រព័ន្ធ និងអ៊ីមែល ហើយលោកអ្នកត្រូវទាញយកព័ត៌មានបង់ប្រាក់ពីក្នុងប្រព័ន្ធ ឬអ៊ីមែល ដើម្បីធ្វើការទូទាត់ថ្លៃសេវាទៅតាមធនាគារជាដៃគូរបស់ក្រសួង។
- លោកអ្នកនឹងទទួលបានអ៊ីមែលបន្ថែមទៀត ប្រសិនជាមានការស្នើសុំកែសម្រួលព័ត៌មាន ឬស្នើសុំឯកសារបន្ថែមពីមន្ត្រីត្រួតពិនិត្យ។
- លោកអ្នកនឹងទទួលបាន **សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ** ក្នុងរយៈពេល **១០ថ្ងៃ** នៃថ្ងៃធ្វើការ *(ប្រសិនបើព័ត៌មានដែលបានបំពេញពិតជាត្រឹមត្រូវ និងពិតប្រាកដ)*។

## ៦.២-ការស្នើសុំក្នុងនាមជាកម្មករនិយោជិត





1 បញ្ចូលអ៊ីមែល ឬលេខទូរស័ព្ទ និងលេខសម្ងាត់ដែលលោកអ្នកបានបង្កើត នៅពេលចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ

2 ចុចលើពាក្យថា "**ចូល**" ដើម្បីចូលស្នើសុំប្រើប្រាស់សេវា

☞ បន្ទាប់ពីចុចលើពាក្យថា "**ចូល**" រួចមក នោះប្រព័ន្ធនឹងបង្ហាញដូចខាងក្រោម៖



1 **ព័ត៌មាននៅក្នុងប្រអប់ពណ៌ក្រហម៖** ជាទិន្នន័យដែលទាញយកមកដោយស្វ័យប្រវត្តិ បន្ទាប់ពីបញ្ចូលលេខឯកសារវិញ្ញាបនបត្រពិនិត្យកាយសម្បទា

2 **ព័ត៌មាននៅក្នុងប្រអប់ពណ៌ខៀវ៖** ជាទិន្នន័យដែលត្រូវបំពេញបន្ថែម ដូចជាកម្រិតវប្បធម៌ និងព័ត៌មានការងារ និងត្រូវទាញយកគំរូវិញ្ញាបនបត្រមុខរបរ ដើម្បីឱ្យរោងចក្រ សហគ្រាសបញ្ជាក់ រួចស្កេនភ្ជាប់មកប្រព័ន្ធវិញ ក្នុងទម្រង់ជា JPG, JPEG, PDF ដែលមានទំហំក្រោម 5MB

3 ចុចលើពាក្យថា "**រក្សាទុក និងបញ្ជូន**" ដើម្បីបញ្ជូនព័ត៌មានដែលបានបំពេញ សម្រាប់ស្នើសុំប្រើប្រាស់សេវា

④ ចុចលើពាក្យថា "**ចាកចេញ**" ដើម្បីបោះបង់ការស្នើសុំប្រើប្រាស់សេវា

☞ បន្ទាប់ពីចុចលើពាក្យថា "**រក្សាទុក និងបញ្ជូន**" រួចមក នោះប្រព័ន្ធនឹងបង្ហាញដូចខាងក្រោម៖




- លោកអ្នកនឹងទទួលបានសារបញ្ជាក់ថាសំណើរបស់អ្នកត្រូវបានបញ្ជូនដោយជោគជ័យទាំងនៅក្នុងប្រព័ន្ធ និងអ៊ីមែល ហើយលោកអ្នកត្រូវទាញយកព័ត៌មានបង់ប្រាក់ពីក្នុងប្រព័ន្ធ ឬអ៊ីមែល ដើម្បីធ្វើការទូទាត់ថ្លៃសេវាទៅតាមធនាគារជាដៃគូរបស់ក្រសួង។
- លោកអ្នកនឹងទទួលបានអ៊ីមែលបន្ថែមទៀត ប្រសិនជាមានការស្នើសុំកែសម្រួលព័ត៌មាន ឬស្នើសុំឯកសារបន្ថែមពីមន្ត្រីត្រួតពិនិត្យ។
- លោកអ្នកនឹងទទួលបាន **សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ** ក្នុងរយៈពេល **១០ថ្ងៃ** នៃថ្ងៃធ្វើការ *(ប្រសិនបើព័ត៌មានដែលបានបំពេញពិតជាត្រឹមត្រូវ និងពិតប្រាកដ)*។